**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០៦៦៧ សហវ

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០០៥

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបិទត្រាពន្ធគយលើទំនិញមួយចំនួនដែលនាំចូល ក្រោមរបបនាំចូលស្ថាពរ ដោយបង់ពន្ធ និង អាករ តាមច្បាប់ជាធរមាន

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមជូនដំណឹងដល់អាជីវករទាំងអស់ដែលជាអ្នកនាំចេញ នាំចូល ម្ចាស់អាជីវកម្មដ្ឋាន សន្និធិ ចរាចរ ចែកចាយដុំ ឬ រាយ ឱ្យបានជ្រាបថា មុខទំនិញនាំចូលដោយបង់ពន្ធ អាករ តាមច្បាប់ជាធរមាន ហើយត្រូវ បិទត្រាពន្ធគយ ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៦តទៅ មានដូចខាងក្រោម៖

| ល.រ | មុខទំនិញ | របៀបបិទត្រាពន្ធគយ |
|---|---|---|
| ០១ | ស្រាគ្រប់ប្រភេទ | បិទលើដប |
| ០២ | ស្រាបៀរ | បិទលើកេស |
| ០៣ | ទឹកក្រូច | បិទលើកេស ឬសំបកវេចខ្ចប់ |
| ០៤ | ទឹកសណ្តែក ចាហួយ ទឹកត្រចៀកកាំ | បិទលើកេស |
| ០៥ | ទឹកដមផ្លែឈើ | បិទលើកេស |
| ០៦ | ទឹកដោះគោខាប់ | បិទលើកេស |
| ០៧ | ទឹកដោះគោគ្រប់ប្រភេទក្រៅពីទឹកដោះគោខាប់ | បិទលើកេស |
| ០៨ | ទឹកបរិសុទ្ធម៉ាក EVIAN | បិទលើកេស |
| ០៩ | ទឹកបរិសុទ្ធម៉ាកផ្សេងទៀតក្រៅពី EVIAN | បិទលើកេស |
| ១០ | ភេសជ្ជៈផ្សេងទៀត | បិទលើកេស |
| ១១ | ផ្លែឈើស្រស់ និង ក្រៀមគ្រប់ប្រភេទ(ផ្ទុកក្នុងកេស) | បិទលើកេស |
| ១២ | បន្លែ ឬ ផ្លែឈើកំប៉ុង | បិទលើកេស |
| ១៣ | ត្រី ឬ សាច់កំប៉ុង | បិទលើកេស |
| ១៤ | នំគ្រប់ប្រភេទដាក់ក្នុងកេស ឬធុងចំណុះលើសពី១០លីត្រ | បិទលើកេស ឬសំបកវេចខ្ចប់ |

| | | |
|---|---|---|
| ១៥ | មី ឬ គុយទាវកញ្ចប់ កំប៉ុង | បិទលើកេស ឬសំបកវេចខ្ចប់ |
| ១៦ | ម្សៅមី បាវ ឬ កញ្ចប់ | បិទលើបាវ ឬសំបកវេចខ្ចប់ |
| ១៧ | ប៊ីចេងដាក់កេស ឬ កញ្ចប់ | បិទលើកេស ឬសំបកវេចខ្ចប់ |
| ១៨ | ទឹកត្រី ទឹកស៊ីអ៊ីវ ទឹកជ្រលក់ គ្រប់ប្រភេទ | បិទលើកេស |
| ១៩ | ប្រេងឆាកំប៉ុង ដប ផ្ទុកក្នុងកេស ឬផ្ទុកក្នុងសំបកវេចខ្ចប់ចំណុះលើសពី១០លីត្រ | បិទលើកេស ឬសំបកវេចខ្ចប់ |
| ២០ | គ្រឿងឧបភោគ បរិភោគ ផ្សេង១ទៀត | បិទលើកេស |
| ២១ | បារី HERO | បិទលើកេស |
| ២២ | បារី JET | បិទលើកេស |
| ២៣ | បារី 555, MALBORO & MILD SEVEN | បិទលើកេស |
| ២៤ | បារីផ្សេង១ទៀត | បិទលើកេស |
| ២៥ | ប្រេងម៉ាស៊ីន កំប៉ុង ដបដែលផ្ទុកក្នុងកេស ឬផ្ទុកក្នុងសំបកវេចខ្ចប់ចំណុះលើសពី១០លីត្រ | បិទលើកេស ឬសំបកវេចខ្ចប់ |
| ២៦ | ក្រណាត់ | បិទលើចុងគី រ៉ូឡូ ឬសំបកវេចខ្ចប់ |
| ២៧ | ម៉ាស៊ីន VTR , VCD , DVD | បិទលើកេស |
| ២៨ | ទូរទស្សន៍ពណ៌ | បិទលើកេស |
| ២៩ | ទូរទស្សន៍ ស ខ្មៅ | បិទលើកេស |
| ៣០ | ម៉ាញ៉េគ្រប់ប្រភេទ | បិទលើកេស |
| ៣១ | ម៉ាស៊ីនត្រជាក់ | បិទលើកេស |
| ៣២ | ឆ្នាំងអគ្គិសនីសំរាប់ចំអិនអាហារ | បិទលើកេស |
| ៣៣ | ចង្ក្រានចំអិនអាហារ ( ប្រើឧស្ម័ន ឬ អគ្គិសនី) | បិទលើកេស |
| ៣៤ | ម៉ាស៊ីនបោកគក់ | បិទលើកេស |
| ៣៥ | ម៉ាស៊ីនថតគ្រប់ប្រភេទ ( រូបភាព , វីដេអូ ) | បិទលើកេស( មួយសន្លឹកសំរាប់មួយគ្រឿង) |
| ៣៦ | ទូទឹកកក ទូភ្លាស្សេ ប្រើអគ្គិសនី | បិទលើកេស |
| ៣៧ | អាគុយចាប់ពី 40Aឡើង | បិទលើកេស |
| ៣៨ | អាគុយក្រោម 40A | បិទលើកេស |
| ៣៩ | សំបកកង់រថយន្ត | បិទលើសំបកកង់ |
| ៤០ | សំបកកង់ម៉ូតូថ្មី | បិទលើសំបកកង់ |
| ៤១ | សាប៊ូគ្រប់ប្រភេទ ( ម្សៅ ដុំ និង រាវ ដាក់ក្នុងកេស) | បិទលើកេស |
| ៤២ | ទឹកអប់គ្រប់ប្រភេទ | បិទលើកេស |
| ៤៣ | ក្រែម ម្សៅ ឡេ គ្រប់ប្រភេទ | បិទលើកេស |
| ៤៤ | គ្រឿងតុបតែងកែលំអ អនាម័យខ្លួនប្រាណផ្សេងទៀត ដាក់ក្នុងកេស | បិទលើកេស |

| | | |
|---|---|---|
| ៤៥ | ថ្នាំដុសធ្មេញដាក់ក្នុងកេស | បិទលើកេស |
| ៤៦ | ប្រេងកូឡាគ្រប់ប្រភេទ | បិទលើកេស |
| ៤៧ | ប្រេងខ្យល់គ្រប់ប្រភេទ | បិទលើកេស |
| ៤៨ | ថ្មពិលដាក់ក្នុងកេស | បិទលើកេស |
| ៤៩ | ក្រដាសគ្រប់ប្រភេទ រ៉ូឡូ កេស ឬ រ៉ាមលើសពី១០គ.ក្រ | បិទលើរ៉ូឡូ កេស រ៉ាមធំ (បិទលើរ៉ាម) |

ក្រដាសត្រាពន្ធគយដែលមានបោះត្រាសំគាល់លើនោះដោយការិយាល័យ ឬសាខាគយ និង រដ្ឋាករ ដែលពាក់ព័ន្ធ ត្រូវបិទមួយសន្លឹកលើកេស ឬសំបកវេចខ្ចប់ទំនិញ ដូចមានបញ្ជាក់ក្នុងតារាងខាងលើត្រង់កន្លែងណាមួយក៏បាន និងកំណត់តំលៃ ៥០់.០០ ក្នុងមួយសន្លឹក ។

ចំពោះទំនិញនាំចូលតាមកុងតឺន័រ មន្ត្រីគយ-រដ្ឋាករ មានសមត្ថកិច្ច ត្រូវប្រគល់ត្រាពន្ធគយតាម បរិមាណស្របតាម បង្កាន់ដៃពន្ធជូនម្ចាស់ឬ តំណាងម្ចាស់ទំនិញនាពេលអនុញ្ញាតឱ្យយកទំនិញចេញពីគយ ។ ម្ចាស់ ឬតំណាងម្ចាស់ទំនិញ ត្រូវចាត់ចែង បិទត្រាពន្ធគយទាំងនោះភ្លាមនាពេលរើទំនិញចេញពីកុងតឺន័ររបស់ខ្លួន។

បណ្តាអាជីវករដែលពាក់ព័ន្ធ ត្រូវអនុវត្តអោយបានត្រឹមត្រូវតាមសេចក្តីជូនដំណឹងនេះសំរាប់ទំនិញដែលផ្ទុកចូលមធ្យោបាយដឹកជញ្ជូនដើម្បីនាំចូលមកកម្ពុជា ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៦ នេះតទៅជាកំហិត។ ក្នុងករណីដែលមន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ចរកឃើញថា ទំនិញទាំងនោះមិនមានបិទត្រាពន្ធគយ ស្របតាមការកំណត់ខាងលើទេ ទោះជាកំពុងចរាចរ លើផ្ទៃប្រទេស ឬកំពុង ស្ថិតនៅក្នុងភណ្ឌាគារទំនិញនានាក៏ដោយ នឹងត្រូវចាត់ទុកជាទំនិញល្មើស ដែលនឹងត្រូវរងនូវការបង្ខំអោយបង់ពន្ធ និង ពិន័យតាមច្បាប់ជាធរមាន ។

សេចក្តីជូនដំណឹងទាំងឡាយណាដែលពាក់ព័ន្ធនឹងការប្រើប្រាស់ត្រាពន្ធគយដែលមានកន្លងមក និង មានខ្លឹមសារផ្ទុយត្រូវចាត់ទុកជានិរាករណ៍ ។

អាស្រ័យហេតុនេះ សូមលោកឧកញ៉ា លោកជំទាវ អស់លោក លោកស្រី ទាំងអស់ដែលជាអាជីវករពាក់ព័ន្ធ មេត្តាសហការអនុវត្តតាមសេចក្តីជូនដំណឹងនេះអោយមានប្រសិទ្ធភាព ដើម្បីលើកស្ទួយសីលធម៌ពន្ធដារក្នុងសង្គមកម្ពុជាយើងជាបណ្តើរៗបន្ថែមទៀត ចូលរួមកាត់បន្ថយអោយបានជាអតិបរមានូវអំពើរត់គេចពន្ធ ឬ ការឆ្លៀតឱកាសល្មើសច្បាប់នានាជាមិនខាន ។

<u>ចម្លងជូន</u> :

- ទីចាត់ការគយ និង រដ្ឋាករ
(ដើម្បីផ្សព្វផ្សាយ និង អនុវត្ត)
- សភាពាណិជ្ជកម្មរាជធានីភ្នំពេញ
(ជូនជ្រាប និង សុំកិច្ចសហការផ្សព្វផ្សាយ)
- ឯកសារ-កាលប្បវត្តិ

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

និង ប្រធានគណៈកម្មការ អន្តរក្រសួង ទប់ស្កាត់

និង បង្ក្រាបអំពើរត់គេចពន្ធ

គាត ឈន់